IFAD
Investing in rural people

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

**កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែល**

**ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ** (ASPIRE )

# បច្ចេកទេសការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

# ធន់ទៅ នឹងការប្រែប្រួលអាកាសធាតុ







ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ ២០១៦

**រៀបចំដោយ** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

**ឧបត្ថម្ភដោយ** : រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម(IFAD)

# មាតិកា

ទំព័រ

មាតិកា........................................................................................................................................................................................................ 1

មេរៀនទី១: ការជ្រើសរើសទីតាំងដីកស្រែ.................................................................................................................................................... 3

មេរៀនទី២: ការរៀបចំស្រែមុនពេលដាក់ត្រីចិញ្ចឹម........................................................................................................................................ 8

មេរៀនទី៣: ប្រភេទត្រីសម្រាប់កសិករដាក់ចិញ្ចឹមក្នុងស្រែ ...................................................................................................................... 12

មេរៀនទី៤: ការប្រមូលផល និងអនុសាសន៍.................................................................................................................................................. 18

មេរៀនទី៥: ការចិញ្ចឹមត្រីអណ្តែងក្នុងស្រែក្រាលកម្រាលកៅស៊ូប្លាស្ទិក.............................................................................................. 19

មេរៀនទី៦ : ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូច ផ្នែកការចិញ្ចឹមត្រី.................................................... 28

ឯកសារយោង ......................................................................................................................................................................................... 35

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ មូលនិធិអភិវឌ្ឍន៍កសិកម្មអន្តរជាតិ ( IFAD) ដែលបានផ្តល់កម្ចីដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្ត កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ( ASPIRE) មានគោលបំណង កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ របស់គ្រួសារ កសិករក្រីក្រ និងអ្នកងាយរងគ្រោះកសិករខ្នាតតូចនៅកម្ពុជា។ កម្មវិធីបានផ្តល់ថវិកា ដល់អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការអនុវត្ត សមាសភាពទី២ នៃកម្មវិធីគឺអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ក្រោមជាតិ និងមូលដ្ឋាន តាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម និងគ្រប់គ្រងចំណេះដឹង និងពង្រឹងធនធានមនុស្សសម្រាប់ ផ្សព្វផ្សាយកសិកម្ម។

បម្រែបម្រួលអាកាសធាតុ មានការប្រែប្រួលខ្លាំង រដូវដែលប្លាស់ប្តូរ បង្កឲ្យមានផលប៉ះពាល់ដល់ជីវភាព រស់នៅរបស់កសិករ និងផលប៉ះពាល់ដល់របរកសិកម្ម ទទួលប្រាក់ចំណូលទាបដូច្នេះហើយទើបកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ រៀបចំឯកសារផ្តល់ចំណេះដឹងនេះឡើងដើម្បីឆ្លើយតបនឹង បម្រែបម្រួលអាកាសធាតុ ឲ្យបានទាន់ពេលវេលា ដែលជាតម្រូវការរបស់កសិករខ្នាតតូចគ្រប់ៗគ្នា ទាំងក្នុងនឹងក្រៅគម្រោងផងដែរ ។

យើងសង្ឃឹមថាឯកសារនេះ និងជួយដល់ មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយ បង្ហាត់ពីបច្ចេកទេសការចិញ្ចឹម ត្រីជាលក្ខណៈគ្រួសារដែលឆ្លើយតបទៅ នឹងការប្រែប្រួលអាកាសធាតុ វាជាវិធីសាស្រ្តងាយៗ សាមញ្ញក្នុងការចិញ្ចឹមត្រី ដែលកសិករអាចធ្វើបាន និងទទួលប្រាក់ចំណូលកើនឡើង ។

ឯកសារណែនាំ "**ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ** នេះជា សមិទ្ធិផលថ្មីមួយរបស់កម្មវិធី ASPIRE ភាពជោគជ័យក្នុងដំណើរការរៀបចំសៀវភៅនេះ គឺអាស្រ័យទាំងស្រុងលើកិច្ចសហប្រតិបត្តិការ និងការចូលរួមក្រុមការងារបច្ចេកទេស របស់កម្មវិធីនៃ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# មេរៀនទី១: ការជ្រើសរើសទីតាំងជីកស្រះ

**១.គោលបំណង** ឲ្យអ្នកចូលរួមយល់ដឹងពីៈ

- ឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់នៃការចិញ្ចឹមត្រី
- ការជ្រើសរើសទីតាំងសមស្របដើម្បីជីកស្រះ



ឥទ្ធិពលការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់ការចិញ្ចឹមត្រី

## ២. ឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុ

- ការខ្វះខាតប្រភពទឹក បាត់បង់គុណភាពទឹកស្រះ
- កម្រិតអុកស៊ីសែនរលាយក្នុងទឹកស្រះ មានការថយចុះ ប៉ះពាល់ការដកដង្ហើមរបស់ត្រី
- ក្នុងទឹកស្រះមានកំដៅ ត្រីងាយកើតជម្ងឺនិងស្លាប់ រយៈពេលចិញ្ចឹមខ្លី ទិន្នផលត្រីចិញ្ចឹមថយចុះ
- កសិករឈប់ចិញ្ចឹមត្រី

## ៣.គុណសម្បត្តិនៃការចិញ្ចឹមត្រី

- ប្រភពប្រូតេអ៊ីនគុណភាពខ្ពស់ ជួយទ្រទ្រង់ជីវភាព ជាប្រភពប្រាក់ចំណូលបន្ថែម
- អាចចិញ្ចឹមរួមគ្នាជាមួយប្រភេទកសិកម្មដទៃទៀត និង អាចជួយកែលំអការគ្រប់គ្រងទឹកក្នុងកសិដ្ឋាន



ប្រភពប្រូតេអ៊ីន



ចិញ្ចឹមជាមួយប្រភេទដំណាំផ្សេងទៀត




ប្រភពប្រាក់ចំណូល

ដើម្បីឆ្លើយតប និងបម្រែបម្រួលអាកាសធាតុ កសិករចិញ្ចឹមត្រីគួរអនុវត្តៈ

### ❖ ការជ្រើសរើសទីតាំងសមស្របសម្រាប់ជីកស្រះ

- ងាយស្រួលចេញចូលប្រចាំថ្ងៃ ឲ្យចំណីត្រី ពិនិត្យគុណភាពទឹក ដាក់ជី និងពិនិត្យជម្ងឺ
- ដីដក់ទឹកបានយ៉ាងតិច ៦ ខែ ពិសេសរដូវប្រាំង
- ជិតលំនៅដ្ឋាន  មិនលិចទឹកនៅរដូវវស្សា មិនមានដើមឈើធំ ឬ គុម្ពឬស្សី នៅក្បែរស្រះ ជិតប្រភពទឹកស្រះជាប់និងស្រែ
- ឆ្ងាយពីស្រែ ឬដីដែលប្រើប្រាស់ថ្នាំ សម្លាប់សត្វល្អិត ឬសារធាតុពុល។



ដំណើរការជ្រើសរើសទីតាំង



ស្រះនៅជិតផ្ទះងាយស្រួលគ្រប់គ្រង



មិនត្រូវជីកស្រះមានដើមឈើធំៗព័ទ្ធជុំវិញ



មិនត្រូវជីកស្រះជិតតំបន់ប្រើប្រាស់ថ្នាំពុល

### ❖ គុណភាពដី

- ដីឥដ្ឋ រក្សាទឹកបាន រយៈពេល ៦ ទៅ ៨ខែ
- ដីករន្ធទំហំ ៦០សង្ទីម៉ែត្រ × ៦០សង្ទីម៉ែត្រ និងជម្រៅ ៨០សង្ទីម៉ែត្រ ហើយបូមទឹកបញ្ចូល
- ២ ទៅ ៣ថ្ងៃ រណ្តៅមានទឹកខ្លះ នោះដីមានសភាពល្អសម្រាប់ជីកស្រះចិញ្ចឹមត្រី
- ដីជ្រាយទន់តាមធម្មជាតិ ងាយស្រួលក្នុងការជីកស្រះ។

### ❖ ស្រះត្រី

- បួនជ្រុងទ្រវែង ទំហំ ២០០ ទៅ ៣០០ម៉ែត្រការ៉េ

ដើម្បីឆ្លើយតបនិងបម្រែបម្រួលអាកាសធាតុ និងរក្សាទឹកបានយូរជាពិសេសរដូវប្រាំង ស្រះចិញ្ចឹមត្រីគួរជីកជម្រៅៈ

### ❖ ចំពោះស្រះចាស់

- សំអាតបាតស្រះ និងជីកឲ្យបាន ជម្រៅពី ២.៥ម៉ែត្រ ទៅ ៣.០ម៉ែត្រ
- មានជម្រេលបាតស្រះទៅជ្រុងម្ខាង ស្រះ

### ❖ ការជីកស្រះចិញ្ចឹមត្រីថ្មី

#### ១. ការរៀបចំទីតាំង

- កាប់ដើមឈើ សំអាតស្មៅ រុក្ខជាតិ និងថ្មចេញពីទីតាំងស្រះ
- ទុកដីស្រទាប់លើខ្លះសម្រាប់ទុកដាំស្មៅជុំវិញស្រះ
- វាស់ទីតាំង និងដាក់សញ្ញាសំគាល់ទីតាំងដែលត្រូវជីក
- រាងចតុកោណកែង ជម្រៅពី ២.៥ម៉ែត្រ ទៅ ៣.០ម៉ែត្រ
- បាតស្រះមានជម្រាលទៅម្ខាងនៃជ្រុងស្រះ ងាយស្រួល ប្រមូលផល
- មានជើងទេរ អាស្រ័យប្រភេទដី ជៀសវាងការបាក់ច្រាំងស្រះ នាំឲ្យពិបាកក្នុងការប្រមូលផល
- ទំនប់ការពារ ការហូរចូលកាកសំណល់មិនល្អ ឬសារធាតុពុលចូលក្នុងស្រះ
- ដាំស្មៅលើទំនប់ស្រះ ការពារការហូរច្រោះបាក់ដីនៅពេលមានភ្លៀងធ្លាក់

- បង្កប់បំពង់ សម្រាប់បង្ហូរទឹកចូលស្រះ
- របងព័ទ្ធជុំវិញ ការពារសត្វពាហនៈ ចុះស្រះ ខូចភ្លឺ ល្អក់ទឹក ការពារក្មេងលេងក្បែរស្រះ និងលង់ទឹកស្រះ
- រណ្តៅជីលាមកសត្វ ជាប់និងភ្លឺស្រះ ងាយស្រួលបង្ហូរទឹកជីចូលក្នុងស្រះចិញ្ចឹមត្រី ទំហំ ២ ម៉ែត្រ x ១ម៉ែត្រ ជម្រៅ ១ ម៉ែត្រ

| **ប្រភេទដី** | **កម្រិតជីកជម្រៅ** |
|---|---|
| ល្បាយដីឥដ្ឋ | ១ ម៉ែត្រ |
| ល្បាយដីឥដ្ឋ លាយខ្សាច់គ្រួស | ១.៥០ម៉ែត្រ |
| ល្បាយដីខ្សាច់ លាយដីឥដ្ឋ | ១.៥០ម៉ែ ទៅ ២ ម៉ែត្រ |



ជីកស្រះតាមបច្ចេកទេស




គំរូប្លង់សម្រាប់ការជីកស្រះ



បុកបង្ហាប់ភ្លឺ និងជើងទេ



ដាំស្មៅលើភ្លឺស្រះ



គំរូស្រះចិញ្ចឹមត្រី

# មេរៀនទី២: ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម

**១.គោលបំណង** ឲ្យអ្នកចូលរួមយល់ដឹងពីៈ

- វិធីសាស្រ្តកម្ចាត់មេរោគក្នុងស្រះ មុនដាក់កូនត្រីចិញ្ចឹម
- ការបង្កើនសារធាតុចិញ្ចឹមក្នុងស្រះសម្រាប់ត្រី
- វិធានការការពារត្រីកាច និងសត្វផ្សេងៗស៊ីកូនត្រី
- វិធីងាយៗក្នុងការពិនិត្យចំណីធម្មជាតិក្នុងស្រះ សត្វល្អិតប្លង់តុង
- ប្រភេទជីធម្មជាតិមានស្រាប់នៅក្នុងភូមិ បរិមាណត្រូវដាក់ក្នុងស្រះ និងវិធីសាស្រ្ត នៃការប្រើប្រាស់ជីធម្មជាតិ

## ២. ការរៀបចំស្រះ មុនពេលដាក់ត្រីចិញ្ចឹម

### ការប្រើប្រាស់កំបោរ មានសារៈប្រយោជន៍ៈ

- ជួយកែលំអរគុណភាពទឹក និងដីស្រះ ដែលមានជាតិអាស៊ីត
- សម្លាប់សត្វស្រះដែលស៊ីត្រី និងកាត់បន្ថយភាពល្អក់នៃទឹកស្រះ

### ❖ ចំពោះស្រះចាស់



ចាប់ត្រីកាច ស្ងួតភក់បាតស្រះ
(ទុកជម្រៅ ១៥ស.ម ឬ ១ តឹកកន្លះ)



បាចកំបោរ (៥-១០គក្រ ក្នុង ១០០ម៉ែត្រការ៉េ)



ដាក់ជីធម្មជាតិក្រាលបាតស្រះ



បញ្ចូលទឹកក្នុងស្រះដោយប្រើតម្រង



មួយអាទិត្យក្រោយទឹកស្រះពណ៌បៃតងសម្បូរចំណីធម្មជាតិ

❖ **ចំពោះស្រះថ្មី**



បាចកំបោរ ពី ១០ -១៥ គក្រ ក្នុង១០០ ម៉ែត្រការេ



បញ្ចូលទឹកក្នុងស្រះ ១ភាគ ៣ នៃជម្រៅស្រះ

## ៣. របៀបពិនិត្យមើលចំណីធម្មជាតិក្នុងស្រះ



ការប្រើក្រម៉ាជួសទឹកគែមជ្រុងស្រះ



ពិនិត្យរូបភាពសត្វល្អិត ប្លង់តុងក្នុងកែវ



ប្រើថ្នងជួសទឹកគែមជ្រុងស្រែ

## ៤. ប្រភេទជីធម្មជាតិសម្រាប់ដាក់ស្រះត្រី

### ❖ បរិមាណជីធម្មជាតិដាក់ក្នុងស្រះ

- ដាក់ជីជាប្រចាំ ទឹកស្រះមានពណ៌ប៉ៃតង ធ្វើឲ្យត្រីធំធាត់
- ប្រើកំបោរច្រើន ទឹកស្រះស្អុយ ពុល ត្រីងាប់

# បរិមាណជីធម្មជាតិដែលមានប្រយោជន៍សម្រាប់ដាក់ស្រះត្រី

| ប្រភេទជី | កម្រិតដាក់ | ប្រភេទជី | កម្រិតដាក់ |
|---|---|---|---|
| ជីលាមកគោ ក្របី  | ៦០-៨០ គ.ក្រ ក្នុង ១០០ម៉ែត្រការ៉េ | ឬ ជីលាមក មាន់ ទា សើម  | ១០-១៥ គ.ក្រ ក្នុង ១០០ម៉ែត្រការ៉េ |
|  ឬជីលាមក ជ្រូក សើម | ២០-៣៥ គ.ក្រ ក្នុង ១០០ម៉ែត្រការ៉េ | ឬ ជីប៉ៃតង ( ទន្ទ្រានខេត្ត....)  | ២០-៣០ គ.ក្រ ក្នុង ១០០ម៉ែត្រការ៉េ |



ត្រាំក្នុងធុង ឬ រណ្តៅជី ១ សប្តាហ៍



បង្ហូរចូលស្រះ

# មេរៀនទី៣: ប្រភេទត្រីសម្រាប់កសិករដាក់ចិញ្ចឹមក្នុងស្រះ

**១.គោលបំណង** ឲ្យអ្នកចូលរួមយល់ដឹងពីៈ

- ការជ្រើសរើសពូជត្រី ក្នុងស្រុក និងក្រៅស្រុក យកមកចិញ្ចឹមដែលធន់ នឹងការប្រែប្រួលអាកាសធាតុ

## ២. ប្រភេទពូជត្រី ក្នុងស្រុក និងក្រៅស្រុក

| ប្រភេទត្រីក្នុងស្រុក | | | ប្រភេទត្រីក្រៅស្រុក |
|---|---|---|---|
| ត្រីឆ្ពិន  | ត្រីព្រលូង  | ត្រីក្រាញ់  | ត្រីទីឡាព្យា  |
| ត្រីកន្ធរ  | ត្រីប្រា  | ត្រីកាបឥណ្ឌា(ត្រីរ៉ូហ៊ូ)  | ត្រីកាបសាមញ្ញ  |
| ត្រីកាហែ  | ត្រីត្រចៀកដំរី  | ត្រីទីឡាព្យា  | ត្រីកាបស  |
| បង្កង  | ត្រីអណ្ដែង  | | ត្រីកាបឥណ្ឌា (ត្រីម្រិហ្គាល់)  |

## ២. ប្រភេទពូជត្រី សមស្របសម្រាប់កសិករចិញ្ចឹម

- ធន់និងជម្ងឺ ងាយរកពូជដាក់ចិញ្ចឹម មានតម្លៃលើទីផ្សារ ស៊ីចំណីធម្មជាតិអាចរកបានក្នុងមូលដ្ឋាន និងងាយចិញ្ចឹមក្នុងស្រះមានទឹក ៦ទៅ៨ខែ

### ❖ ប្រភេទកូនត្រីពូជដែលគួរចិញ្ចឹម

- ត្រីឆ្ពិន កន្ធរ កាបឥណ្ឌា ទីឡាព្យ៉ា កាបសាមញ្ញ

### ❖ ចំនួនកូនត្រីពូជចិញ្ចឹម

- ចិញ្ចឹមត្រីចម្រុះពីបីប្រភេទឡើង អាចស៊ីចំណីធម្មជាតិ ក្នុងស្រះដែលកើតពីការដាក់ជី
- កូនត្រីដាក់ចិញ្ចឹម ៥ក្បាល ក្នុង១ម៉ែត្រការ៉េ

### ❖ ការដឹកជញ្ជូនកូនត្រី

- ប្រភពទឹកដូចគ្នាពីទឹកដែលកូនត្រីកំពុងរស់នៅ ស្អាតល្អ សីតុណ្ហភាពត្រជាក់នៅពេលដឹកជញ្ជូន កុំឲ្យត្រូវពន្លឺថ្ងៃច្រើនពេក
- ទំហំថង់ ៦០សម × ៨០ សម

  ផ្ទុកកូនត្រីប្រវែង ៥សម បាន៥០០ក្បាល។



ការដឹកជញ្ជូនផ្លូវជិត



ការដឹកជញ្ជូនផ្លូវឆ្ងាយ



ខ្ចប់កូនត្រី និងបញ្ចូលខ្យល់អុកស៊ីសែន

## ❖ ការដាក់កូនត្រីចិញ្ចឹម



ត្រាំថង់កូនត្រីក្នុងទឹកស្រះ ៣ ទៅ ៥នាទី



ការស្រាយមាត់ថង់បាចទឹកស្រះបញ្ចូលថង់



លែងកូនត្រីចេញពីថង់ដោយសន្សឹមៗ





ការវាស់តាមដាន ទំហំកូនត្រី

## ❖ ប្រភេទចំណីដែលមាននៅមូលដ្ឋានកសិករ



ជន្លេន



កន្ទក់



ចកបាយទា



កាកសំណល់បន្លែ





កណ្ដៀរ

## ❖ ការផ្តល់ចំណីបន្ថែម

- អាកាសធាតុត្រជាក់ ត្រី មិនស៊ីចំណី និងកុំឲ្យខូចគុណភាពទឹកស្រះដោយកាកសំណល់ចំណីត្រូវ៖
  - ចំអិនមុននឹងដាក់ឲ្យត្រីស៊ី ដាក់ក្នុងកញ្ជ្រែងពន្លិចចូលក្នុងទឹកស្រះ និងដាក់ចំណីពេលព្រឹកជិតថ្ងៃត្រង់ និងពេលរសៀល
  - កន្ទក់ ៥០ភាគរយ ចុងអង្ករ ១០ភាគរយ ពោតឬសណ្តែកសៀង ២០ភាគរយ និងត្រីហាល ២០ភាគរយ
- បន្ថយបរិមាណចំណីពេលត្រីមានជម្ងឺ និងអាកាសធាតុត្រជាក់



កន្ទក់



ចុងអង្ករ





សណ្តែកសៀង ឬពោត



កូនត្រីហាល



ចំណីដែលចំអិនរួច





ការដាក់ចំណីឲ្យត្រីស៊ីដោយប្រើកញ្ជ្រែង

## ❖ ការគ្រប់គ្រងទឹកស្រះចិញ្ចឹមត្រី

- ទឹកស្រះជម្រៅ ៣ភាគ៤នៃជម្រៅស្រះរដូវវស្សា អាចរក្សាទឹកបានច្រើននៅរដូវប្រាំង និងចិញ្ចឹមត្រីបានយូរ
- បូមទឹកបញ្ចូលស្រះ មានស្បៃហាប៉ាតូច ត្រងទឹកការពារត្រីកាចចូលស្រះ
- បូមទឹកអណ្តូងបញ្ចូលក្នុងទឹកស្រះចិញ្ចឹមត្រីរដូវប្រាំង។ បូមទឹកបំពេញទឹកស្រះជាប្រចាំថ្ងៃប្រសិនបើ ទឹកស្រះមានរំហួតនិងជម្រាបខ្លាំង។

## ❖ របៀបដាក់ជីក្រោយពេលលែងកូនត្រី

- បង្ហូរទឹកជីលាមកសត្វចូលក្នុងស្រះ ពេលមានពន្លឺថ្ងៃគ្រប់គ្រាន់ ជៀសវាងពេលជិតភ្លៀង កំពុងភ្លៀង និងក្រោយភ្លៀង
- បង្ហូរគ្មានពន្លឺថ្ងៃ ទឹកស្រះខ្យល់ខ្វះអុកស៊ីសែន បង្កើតជាតិពុលក្នុងស្រះ កូនត្រីងាប់
- ជៀសវាងទឹកស្រះស្អុយ ឬទឹកមានពណ៌បៃតងខ្លាំង





កសិករអាចប្រើពាងទឹក ឬកង់អណ្តូងលូជារណ្តៅជី

## ❖ ការគ្រប់គ្រងស្រះចិញ្ចឹមត្រី





ឧស្សាហារណ៍ផ្តល់ចំណីបន្ថែម



ឧស្សាហារណ៍ប្តូរជីលាមកសត្វក្នុងរណ្តៅ



រក្សាគុណភាពទឹកក្នុងស្រះ

# មេរៀនទី៤: ការប្រមូលផល និងអនុសាសន៍

## ១. ការប្រមូលផល

- ដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ទុកទឹកស្រះសម្រាប់ប្រើប្រចាំថ្ងៃ ស្រោចដំណាំ និងសម្រាប់សត្វពាហនៈ មិនបូមពង្រីកទឹកស្រះចេញដើម្បីប្រមូលផល ក្នុងរដូវប្រាំង
- ប្រមូលផលលក់ និងរក្សាទឹកស្រះរដូវប្រាំង ដោយប្រើសន្ទូច មង អួន ហ៊ុម ឬប្រើសំណាញ់។





គ្របស្បៃកាត់បន្ថយការឡើងកំដៅទឹកស្រះចិញ្ចឹមត្រី

## ២. អនុសាសន៍

- ជាជម្រកកាត់បន្ថយការកើនឡើងកំដៅទឹកស្រះចិញ្ចឹមត្រីកសិករគួរៈ
  - ដាំបន្លែទ្រើងគ្រប លើផ្ទៃស្រះ ៣០ភាគរយ លើផ្ទៃស្រះ
  - គ្របស្បៃនីឡុង ឬប្រក់ស្លឹកដូង លើផ្ទៃស្រះ ២០ភាគរយ ផ្ទៃស្រះ
- កុំត្រាំស្លឹកត្នោត ឬដើមឈើស្រស់ ក្នុងទឹកស្រះ ខូចគុណភាពទឹកស្រះ និងត្រីងាប់
- មានអណ្តូងទឹកអាចបូមទឹកបន្ថែមចូលក្នុងទឹកស្រះបានរដូវប្រាំង
- កុំប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតជិតស្រះចិញ្ចឹមត្រី បង្ហូរពីលើស្រះចិញ្ចឹមត្រី ដាក់ចក អណ្តែតពេញផ្ទៃស្រះ
- កុំលាងធុងបាញ់ថ្នាំពុលក្នុងស្រះកំពុងចិញ្ចឹមត្រី បោកគក់ខោអាវក្នុងស្រះកំពុងចិញ្ចឹមត្រី។





# មេរៀនទី៥: ការចិញ្ចឹមត្រីអណ្តែងក្នុងស្រះក្រាលកម្រាលកៅស៊ូប្លាស្ទិក

១. **គោលបំណង** ក្រោយវគ្គបណ្តុះបណ្តាលសិក្ខាកាមនឹងចេះ៖

- របៀបជីកស្រះ ការរៀបចំស្រះ ក្រាលកម្រាលប្លាស្ទិក សម្រាប់ចិញ្ចឹមត្រីអណ្តែង
- ចំណីធម្មជាតិ និងចំណីផ្សំសម្រាប់ត្រីអណ្តែង
- ការតាមដាន និងគ្រប់គ្រងស្រះចិញ្ចឹមត្រី

## ២.ការជ្រើសរើសទីតាំងជីកស្រះចិញ្ចឹមត្រី

- ជិតផ្ទះស្រួលគ្រប់គ្រង ផ្តល់ចំណី ពិនិត្យគុណភាពទឹក មើលថែទាំ តាមដានសកម្មភាព និងសុខភាពត្រី
- វាលខ្ពស់ស្រឡះ មិនលិចទឹកនៅរដូវវស្សា មានខ្យល់ ពន្លឺចេញចូល បានល្អគ្រប់គ្រាន់
- ជិតប្រភពទឹក ស្រួលផ្លាស់ប្តូរទឹកថ្មី ករណីត្រីពុល និងមានជម្ងឺ
- ទឹកស្រះមានក្លិនស្អុយ ឬ កខ្វក់ ផ្លាស់ប្តូរ ១ភាគ ៣ ទៅ ពាក់កណ្តាល ប្រើប្រភពទឹក ត្រពាំង បឹង បួរ ស្រះ ប្រឡាយ ត្រីមានសុខភាពល្អ ធំធាត់ ទិន្នផលខ្ពស់។



ជីកស្រះជិតផ្ទះងាយស្រួលគ្រប់គ្រង និងថែទាំ

## ៣.លក្ខណៈស្រះចិញ្ចឹមត្រី

- បណ្តោយ៤ម ទទឹង២ម ជម្រៅ០.៨ម ផ្ទៃ ៨ ម៉ែត្រការ៉េ
- បណ្តោយ៣ម ទទឹង២ម ជម្រៅ០.៨ម ផ្ទៃ ៦ម៉ែត្រការ៉េ
- តាមលទ្ធភាពកសិករ

ការពារទឹកលិចស្រះពេលភ្លៀងធ្លាក់ខ្លាំងត្រូវ៖

- ទំនប់ ភ្លឺ ទប់សង្កត់កម្រាលកៅស៊ូប្លាស្ទិក និងព័ទ្ធសំណាញ់ជុំវិញស្រះ
- បង្កប់ទុយយោបង្ហូរទឹកបញ្ចេញបញ្ចូលទឹកពីស្រះ



ទំហំស្រះដែលអាចចិញ្ចឹមត្រីអណ្តែងបាន

## ៤. របៀបជីកស្រះចិញ្ចឹម

- វាស់បណ្តោយ ទទឹងស្រះ បោះបង្គោលជ្រុងទាំង៤ ចងខ្សែព័ទ្ធជុំវិញ
- ជើងទេ រំលីង សំអាត ជញ្ជាំងស្រះកុំឲ្យមានកំទេចឈើ ដុំថ្ម ការពារធ្លាយរហែកកៅស៊ូប្លាស្ទិក
- ក្រាលកៅស៊ូប្លាស្ទិកលើស្រះជីករួច
- ដាក់ខ្សាច់ ឬអាចមន៍ដីក្រាលសង្កត់លើជ្រុងទាំង៤បាតស្រះការពារ កម្រាលកៅស៊ូបើងពីបាតស្រះ
- អាចមន៍ដីសង្កត់ជ្រុងទាំង៤គែមស្រះ ការពារកៅស៊ូបើងចេញ



របៀបជីកស្រះ និងរៀបចំស្រះក្រាលកម្រាលកៅស៊ូ

## ៥. ការរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម

- **ស្រះថ្មី៖** គ្មានដុំថ្ម អំបែងកែវ មែកឈើ ឬដែក ធ្លុះធ្លាយកម្រាលកៅស៊ូក្រោយក្រោយពេលក្រាល និងបញ្ចូលទឹករួច
- **ស្រះចាស់៖**
  - ប្រមូលផលត្រី បូមទឹកពង្រីង សំអាតកៅស៊ូប្លាស្ទិច កុំឲ្យរហែក ឬធ្លាយ មុននិងក្រោយដាក់កូនត្រីចិញ្ចឹម និងក្រោយបញ្ចូលទឹករួច
  - ភ្លឺស្រះ ទទឹង ០.៥ម៉ែត្រ កំពស់ ០.២ ទៅ០.៣ម៉ែត្រ ព័ទ្ធជុំវិញស្រះការពារ ស្រះលិចទឹកត្រីវាចេញ ពេលមានភ្លៀងធ្លាក់
  - ដាក់ភក់បាតត្រពាំង ឬបឹងក្រាលពីលើបាតស្រះ ០.៥តឹក បន្ថែមជីលាមកសត្វ ពង្រាយបាតស្រះ ០.៥គីឡូក្រាម ក្នុង១ម៉ែត្រការ៉េ
  - បញ្ចូលទឹកដំបូងជម្រៅ ០.២ ទៅ ០.៤ម៉ែត្រ ត្រាំ ៣ ទៅ៥ថ្ងៃ ទឹកព៌ណត្រួយចេកខ្ចី មានចំណីធម្មជាតិ
  - តម្រងស្បៃប្រោះ ដាក់កំប្លោកត្រាំបណ្តែត បញ្ចូលទឹកបន្ថែម ១ភាគ៣ ផ្ទៃទឹកស្រះ កូនត្រីជ្រកអាកាសធាតុក្តៅ (ថ្ងៃត្រង់)
  - របង ឬរបាំងស្បៃហាប៉ា ព្រួលឬស្សីព័ទ្ធជុំវិញភ្លឺស្រះ ការពារត្រីវាចេញ និងសត្វពាហនះបំផ្លាញ
  - ធ្វើទ្រើងដំណាំពីលើ ពាក់កណ្តាលស្រះត្រី កាត់បន្ថយការរំហួតទឹកស្រះ ពេលអាកាសធាតុក្តៅខ្លាំង។ ហាមគ្របពេញផ្ទៃស្រះបាំងពន្លឺព្រះអាទិត្យ។

 

សភាពស្រះត្រៀមលែងកូនត្រី

## ៣. ការលែងកូនត្រីចិញ្ចឹម

- ត្រាំថង់កូនត្រីក្នុងស្រះ ៣ ទៅ ៥នាទី ស៊ីតុណ្ណភាពទឹកក្នុងស្រះ និងក្នុងថង់ មានក្រិតប្រហាក់ប្រហែលគ្នា
- ម៉ោង៩ ទៅ១០ព្រឹក ពន្លឺព្រះអាទិត្យគ្រប់គ្រាន់
- រសៀលមេឃត្រជាក់ ម៉ោង៣ ទៅ៤ មាន អុកស៊ីស្សែនគ្រប់គ្រាន់ក្នុងទឹក។




ការត្រាំថង់មុនលែងកូនត្រី

## ៤. ចំនួនកូនត្រីចិញ្ចឹម

- ទំហំ ៤ ទៅ ៦សង្ទីម៉ែត្រ ៣ថ្នាំងចង្អុលដៃ
- ៤០ ទៅ ៥០ក្បាល ក្នុង១ម៉ែត្រការ៉េស្រះ ។ ស្រះទទឹង ២ម៉ែត្រ បណ្ដោយ ៥ម៉ែត្រ ស្មើ ១០ម៉ែត្រការ៉េ ដាក់ ៥០០ក្បាល។
- ស្រះតូច មិនអាចដាក់បានច្រើនជាង ៤០ ទៅ ៥០ក្បាលបានទេ ត្រីមិនលូតលាស់ល្អ ពុលទឹក មិនស៊ីចំណី និងងាប់។




កូនត្រីដាក់ចិញ្ចឹម

## ៥. ប្រភេទចំណី និងការផ្តល់ចំណី

- **ចំណី** មានក្នុងមូលដ្ឋាន កន្ទក់ កញ្ចុង អង្ករ ស្លឹកដំឡូងជ្វា ពោត ឬ សណ្តែកសៀង កូនត្រីហាល លាយផ្សំចូលគ្នា ចំអិនឲ្យឆ្អិន ទុកឲ្យត្រជាក់មុននិងដាក់ឲ្យស៊ី



កន្ទក់



កញ្ចុងអង្ករ



ស្លឹកដំឡូងជ្វា





ពោត ឬ សណ្តែកសៀង



កូនត្រីហាល





កណ្ដៀរ



ចំណីគ្រាប់



ជន្លេន



ចង្រិត



កណ្តូប



ខ្យង

## ❖ ការផ្តល់ចំណី

- ផ្តល់តិចតួច បន្ទាប់ពីលែងចូលស្រះ ២-៣ម៉ោង
- ថ្ងៃបន្ទាប់ ៣ -៥ភាគរយ ធៀបទម្ងន់ដងខ្លួនត្រីសរុបក្នុងស្រះ ២-៣ដងក្នុងមួយថ្ងៃ ព្រឹកម៉ោង ៨ រសៀល ម៉ោង ៤
- ផ្តល់ទៀងទាត់ និងគ្រប់គ្រាន់
- គោះ ឬគួរទឹកជាសញ្ញាឲ្យចំណី ដាក់ច្រើនកន្លែង
- ការអង្កេតត្រី៖





ត្រីស៊ីឆ្អែតចំណីពីមុន




ត្រីដែលឃ្លានអាហារ



សញ្ញាដែលមានបញ្ហាធ្ងន់ធ្ងរ

❖ **ការវាស់វែងត្រី៖** តាមដានការលូតលាស់របស់ត្រី ធ្វើឡើងរយះពេល២ សប្តាហ៍ម្តង ឬ ពេលផ្លាស់ប្តូរទឹក











❖ **មិនឲ្យផ្តល់ចំណី**


ធាតុអាកាសមិនល្អ ឬប្រែប្រួលភ្លាមៗ


២៤ម៉ោងមុនចាប់ថ្លឹង ឬ ប្រមូលផលត្រី


មិនផ្តល់ចំណី


ត្រីឈឺ

## ៦. ការតាមដាន និងគ្រប់គ្រងស្រះចិញ្ចឹមត្រី

- ទឹកស្រះព័ណបៃតងខ្លាំង ឬខ្មៅ ឬមានក្លិនស្អុយ ផ្លាស់ប្ដូរទឹកកខ្វក់ចេញ ៣០-៤០ ភាគរយ នៃទឹកសរុប
- ផ្លាស់ប្ដូរទឹក ក្រោយដាក់កូនត្រី១ខែ ទឹកស្អាតល្អ គ្មានជាតិពុល
- ពិនិត្យត្រីស៊ីចំណីរាល់ថ្ងៃ ករណីឈប់ស៊ី ឈប់ផ្ដល់ចំណី
- យកកាកសំណល់ធ្លាក់ក្នុងបាតស្រះចេញ
- ការពារការបំផ្លាញពីសត្វពាហនៈ
- កុំឲ្យកំប្លោកដុះលើសពី ១ភាគ៣ នៃស្រះទាំងមូល
- វិធីសាស្ត្រងាយៗនៃការបូមទឹកសំណល់ពីស្រះនិង បំពេញបន្ថែមទឹកថ្មីក្នុងស្រះ



បូមទឹកសំណល់ពីស្រះ និងបំពេញបន្ថែមទឹកថ្មីក្នុងស្រះ

## ៧. វិធីការការពារជម្ងឺ

- ឲ្យចំណីគ្រប់គ្រាន់
- កុំឲ្យចំណីសល់ក្នុងច្រើនក្នុងបាតស្រះ
- ធានាគុណភាពទឹកល្អជានិច្ច
- មិនឲ្យមានកាកសំណល់មិនល្អចូលក្នុងស្រះ
- កែប្រែគុណភាពទឹក កាត់បន្ថយជាតិស្អុយៈ
  - ✓ ប្រើមេដំបែ ឬអ៊ីអឹមផ្សំពីផ្លែឈើ ១០មីលីលីត្រ/មួយម៉ែត្រគីបទឹក





មេដំបែ ឬអ៊ីអឹមផ្សំពីផ្លែឈើ

- ការផ្លាស់ប្តូរទឹកទៀងទាត់រយៈពេល ២សប្តាហ៍ម្តង

## ៨.ការប្រមូលផល



ការប្រមូលផលផ្គត់ផ្គង់ក្នុងគ្រួសារ



ការប្រមូលផលសរុប

# មេរៀនទី៦ : ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូច ផ្នែកការចិញ្ចឹមត្រី

## តើត្រូវធ្វើដូចម្តេចខ្លះ ដើម្បីចាប់ផ្តើមផលិតកម្ម ការចិញ្ចឹមត្រី ?

### ការពិពណ៌នាជាទូទៅ

ការចិញ្ចឹមត្រីជាប្រភពប្រាក់ចំណូលបន្ថែម ផ្តល់ជាតិសាច់ បង្កើតកោសិកាសរីរាង្គផ្សេងៗក្នុងខ្លួន មនុស្ស សត្វ ។ មនុស្សត្រូវការត្រីជារៀងរាល់ថ្ងៃ ដើម្បីយកមកកែច្នៃបរិភោគ ។

### ១. ទំហំដីសម្រាប់ជីកស្រះចិញ្ចឹមត្រី

- ផ្ទៃដីសម្រាប់ជីកស្រះចិញ្ចឹមត្រី តាមលទ្ធភាព ០,៥ហាត ឬ ១ហិកតា (ការចិញ្ចឹមត្រីក្នុងស្រះ)
- ផ្ទៃដីសម្រាប់ធ្វើស្រែ និងចិញ្ចឹត្រី ០,៥ហាត ឬ ១ហិកតា (ការចិញ្ចឹមត្រីក្នុងស្រែ)

### ២. វត្ថុធាតុដើម និងសំភារៈ សម្រាប់ការចិញ្ចឹមត្រី (ផែនការអាជីវកម្ម)

### ៣. ផែនការថវិកា សម្រាប់ប្រតិបត្តិការកសិកដ្ឋានរបស់អ្នក

- លទ្ធភាពនៃថវិកាដែលមាន សម្រាប់ដំណើរការកសិដ្ឋានចិញ្ចឹមត្រី

### ៤. សម្រេចចិត្តជ្រើសរើស ពូជត្រីដែលត្រូវចិញ្ចឹម (តម្រូវការនៅលើទីផ្សារខ្ពស់)

- ធាតុអាកាសៈ ពូជត្រីដែលត្រូវទៅនឹងអាកាសធាតុ
- ពេលវេលា និងកម្លាំងពលកម្មសមស្រប
- ចំណេះដឹងបច្ចេកទេសនៃការចិញ្ចឹម
- សិក្សាអំពីធនធានដែលមានៈ ប្រភពទឹក សម្រាប់កសិដ្ឋានចិញ្ចឹមត្រីរបស់អ្នក តើអាចមានទឹកគ្រប់គ្រាន់នៅក្នុងស្រះរយៈពេល ៦ខែដែរ ឬទេ?
- ចិញ្ចឹមត្រីក្នុងស្រះ៖ ត្រី ទីឡាព្យា,កាបសាមញ្ញ,កាបឥណ្ឌា,ឆ្ពិន......
- ចិញ្ចឹមត្រីក្នុងស្រែ (ត្រីជាមួយដំណាំស្រូវ) ទីឡាព្យា.......
- កសិដ្ឋានភ្ញាស់កូនត្រីពូជ

## ៥. អ្នកផ្គត់ផ្គង់ពូជត្រី

- ទិញពីសហគមន៍ក្នុងមូលដ្ឋាន ឬភ្ញាស់កូនដោយខ្លួនឯង ស្ថានីយផលិតពូជត្រីរបស់រាជរដ្ឋាភិបាល ឯកជនផលិតពូជត្រីដែលមានកូនត្រីពូជល្អៗ
- ការទុកដាក់ និងដឹកនាំកូនត្រីមកកសិដ្ឋានចិញ្ចឹមត្រី

## ៦. ការយល់ដឹងពីការគាំទ្រ ការចិញ្ចឹមត្រីរបស់អ្នក

- ការពិភាក្សាជាមួយមន្ត្រី ឬភ្នាក់ងារផ្សព្វផ្សាយ ដែលនៅជិតអ្នកបំផុតពីជម្ងឺត្រី និងការថែទាំកូនត្រី
- កត្តាដែលមានឥទ្ធិពលលើការផ្គត់ផ្គង់៖ រដូវកាលនៃការចិញ្ចឹម ការប្រែប្រួលអាកាសធាតុ ថ្លៃទំនិញ ផលិតផល ថ្លៃទំនិញផ្សេងៗ ការប្រែប្រួលនៃថ្លៃដើមផលិតកម្ម ប្រភពធនធាន ឬកត្តាផលិតផល
- ដឹងពី ប្រភេទត្រីដែលលក់បានថ្លៃ ខែដែលត្រូវប្រមូលផលត្រី ខែដែលតម្លៃត្រីចុះតម្លៃថោក ខែដែល សំបូរត្រីធម្មជាតិ

## ៧. ផ្លូវថ្នល់ក្នុងការទំនាក់ទំនងទៅផ្សារ

- ប្រជាជនអាចចូលទៅដល់តំបន់របស់អ្នក
- អាចដឹកនាំផលិតផលរបស់អ្នកទៅផ្សារ
- អ្នកទិញអាចមកមើលកសិដ្ឋានចិញ្ចឹមត្រីរបស់អ្នក

# តារាងផែនការអាជីវកម្ម ការចិញ្ចឹមត្រី

កាលបរិច្ឆេទសចាប់ផ្ដើមអាជីវកម្ម៖......................................................

## ១.ចំណាយថ្លៃវត្ថុធាតុដើម

| រាយមុខទំនិញ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| **កូនត្រីពូជ**  | | | | |
| កន្ទក់  | | | | |
| កញ្ចុំងអង្ករ  | | | | |
| បន្លែបៃតង  | | | | |
| ចំណីត្រីបន្ថែម  | | | | |
| ប្រេងសាំងបូមទឹក  | | | | |
| **សរុបចំណាយថ្លៃវត្ថុធាតុដើម** | | | | |

## ២.ចំណាយថ្លៃឧបករណ៍/សម្ភារៈ

| រាយមុខឧបករណ៍/សម្ភារៈ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| សំណាញ់ហាប៉ា  | ចំនួន | | | |
| ម៉ាស៊ីនបូមទឹក  | ចំនួន | | | |
| កញ្ច្រែងដាក់ចំណីត្រី | ចំនួន | | | |
| ចបកាប់  | ចំនួន | | | |
| **សរុបចំណាយថ្លៃឧបករណ៍/សម្ភារៈ** | | | | |

**សរុបចំណាយទាំងអស់** .................................. + .................................. = ..................................

# ប្រតិទិនរដូវកាល នៃការចិញ្ចឹមត្រី តម្រូវការទីផ្សារ និងតម្លៃ

| ល.រ | សកម្មភាព | ប្រតិទិន | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ១ | **ការខារយេនឌ័រ** | | | | | | | | | | | | |
| | បុរស ស្ត្រី ស្ងួង | | | | | | | | | | | | |
| | បុរស ស្ត្រី ច្រូតកាត់ | | | | | | | | | | | | |
| | បុរស ស្ត្រី ចិញ្ចឹមត្រី រួចការងារស្រែចំការ | | | | | | | | | | | | |
| ២ | **ដាក់ត្រីចិញ្ចឹម** | | | | | | | | | | | | |
| | ក្នុងស្រះ (ទីឡាព្យា,កាបសាមញ្ញ,កាបឥណ្ឌា,ឆ្ពិន) | | | | | | | | | | | | |
| | ត្រីក្នុងស្រែ (អណ្តែង,ផ្ទក់, ទីឡាព្យា)<br>▪ រៀបចំដីដាក់ត្រីចិញ្ចឹម | | | | | | | | | | | | |
| ៣ | **ប្រមូលផលត្រី** | | | | | | | | | | | | |
| | ក្នុងស្រះ | | | | | | | | | | | | |
| | ត្រីក្នុងស្រែ | | | | | | | | | | | | |
| ៤ | **ពត៌មានទីផ្សារ** | | | | | | | | | | | | |
| | រាំងមិនសូវសំបូរទឹក(កសិករត្រៀបប្រេងបូមទឹក) | | | | | | | | | | | | |
| | សំបូរត្រីធម្មជាតិ | | | | | | | | | | | | |
| | លក់ត្រីបានថ្លៃ | | | | | | | | | | | | |

## ប្រតិទិនផ្គត់ផ្គង់ទីផ្សារ ការចិញ្ចឹមត្រី

| លរ | ប្រភពអ្នកទិញ | ប្រតិទិន | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ១ | អ្នកប្រើប្រាស់ក្នុងស្រុក | | | | | | | | | | | | |
| ២ | ផ្សារក្នុងស្រុកគោលដៅ | | | | | | | | | | | | |
| ៣ | លក់រាយជាយផ្លូវ | | | | | | | | | | | | |
| ៤ | ផ្សារតូចៗតាមភូមិ | | | | | | | | | | | | |
| ៥ | ហាងនៅក្នុងស្រុក | | | | | | | | | | | | |
| ៦ | ភោជនីដ្ឋានក្នុងស្រុក | | | | | | | | | | | | |
| ៧ | សណ្ឋាគារ | | | | | | | | | | | | |
| ៨ | ផ្ទះលក់ចាប់ហួយ | | | | | | | | | | | | |
| ៩ | ផ្សារទំនើប | | | | | | | | | | | | |

## តារាង ការវិភាគចំណូលចំណាយ ក្នុងការចិញ្ចឹមត្រី

| រាយមុខទំនិញ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| **១.ចំណាយផលិតកម្ម** | | | | |
| **ក.ថ្លៃវត្ថុធាតុដើម** | | | | |
| កូនត្រីពូជ     | ក្បាល | | | |
| កន្ទក់  | គក្រ | | | |
| កញ្ចុងអង្ករ  | គក្រ | | | |
| បន្លែបៃតង  | សរុប | | | |
| ចំណីត្រីបន្ថែម  | គក្រ | | | |
| ប្រេងសាំងបូមទឹក  | លីត្រ | | | |
| ពូជស្រូវ  | គក្រ | | | |
| **សរុបរងថ្លៃវត្ថុធាតុដើម** | | | | |
| **ខ.ថ្លៃឧបករណ៍/សំភារៈ** | | | | |
| សំណាញ់ហាប៉ា  | ម៉ែត្រ | | | |
| ម៉ាស៊ីនបូមទឹក  | ចំនួន | | | |
| កញ្ច្រែងដាក់ចំណីត្រី | ចំនួន | | | |
| ចបកាប់  | ចំនួន | | | |
| **សរុបរងថ្លៃឧបករណ៍/សំភារៈ** | | | | |
| **គ.ថ្លៃពលកម្ម** | | | | |
| ថ្លៃពលកម្មផ្តល់ចំណី និងថែទាំត្រី | នាក់/ថ | | | |

| | | | | |
|---|---|---|---|---|
| សរុបរងថ្លៃពលកម្ម | | | | |
| សរុបចំណាយផលិតកម្ម (ថ្លៃវត្ថុធាតុដើម+សំភារៈ + ពលកម្ម) | | | | |
| ២.ចំណូលៈផលិតផលដែលសម្រេចបាន) | | | | |
| បរិមាណផលត្រី  | គក្រ | | | |
| កូនត្រី    | ក្បាល | | | |
| បរិមាណផលស្រូវ  | គក្រ | | | |
| សរុបរងចំណូលផលិតកម្ម | | | | |
| ៣.ការប្រើប្រាស់ក្នុងគ្រួសារ | | | | |
| ត្រីដែលហូប   | គក្រ | | | |
| សរុបរងការប្រើប្រាស់ក្នុងគ្រួសារ | | | | |
| ៤.បរិមាណ ត្រី ទុកពូជ | | | | |
| កូនត្រីពូជ    | ក្បាល | | | |
| សរុបរងបរិមាណទុកពូជ | | | | |
| សរុបចំណេញ = ចំណូលផលិតកម្ម-ចំណាយផលិតកម្ម | | | | |
| សរុបប្រាក់ចំណេញសុទ្ធ= ចំណេញ -(ប្រើប្រាស់ក្នុងគ្រួសារ+ ទុកពូជ) | | | | |

បញ្ហាកើតមានក្នុងការចិញ្ចឹមត្រី..........................................................................................................................................................

..........................................................................................................................................................................................................

# ឯកសារយោង

១. សៀវភៅកសិករ កម្រងបច្ចេកទេសកសិកម្មល្អៗ ធន់នឹងអាកាសធាតុប្រែប្រួលខែវិច្ឆិកា ឆ្នាំ ២០១៥។ អង្គការ Action Aid, PIN, Save the Children, Oxfam និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

២. បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ឆ្នាំ ២០១៦

៣. World Renew offers a gallery of images from nine countries, a close up look at communities engaged in the work of renewal and building resilience, topics Community Development, June 22, 2015.

៤. Fresh water aquaculture Improvement and Extension Project Evalaution

៥. Home Based Technology for raising Walking catfish in concrete tanks, Fisheries Administration, WISH Project.

៦. រូបភាព A farmer demonstrates a simple pumping method to recycle old water from the plastic bag pond to use as irrigation water, to replenish the pond with new water.

**បោះពុម្ពលើកទី១ ឆ្នាំ២០១៧ ដោយ៖**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃ អគ្គនាយកដ្ឋានកសិកម្ម ក្រោមមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម(IFAD) និងឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា

អាសយដ្ឋាន៖ # ២០០ផ្លូវនរោត្តមសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា

(ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

លេខទូរស័ព្ទ៖ ០២៣ ២២ ១១ ២០

គេហទំព័រ៖WWW.ASPIREKH.ORG